អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# គូគូ កូនដំរី



សូមស្កេនQR Code

កំន្សូរដើរចល　　ធនធានបង្រៀន

Written by Sem Rasin

Illustration by Sem Rasin



កាលពីព្រេងនាយ មានកូនដំរីតូចមួយក្បាលឈ្មោះថា តូតូ។

តូតូមានត្រចៀកធំៗ និងប្រមោយវែងគួរឱ្យស្រឡាញ់ ហើយតូតូរស់នៅក្នុងព្រៃជ្រៅជាមួយម្ដាយរបស់វា។



ថ្ងៃមួយ តូតូបានសួរម្ដាយវាថា «ម៉ាក់ៗ! តើនៅជុំវិញព្រៃដែលយើងរស់នៅមានអ្វីខ្លះ?»
ម្ដាយតូតូញញឹមហើយឆ្លើយថា «នៅជុំវិញនេះ មានពិភពលោកដីធំទូលាយ តែកូនត្រូវប្រយ័ត្ន
កុំដើរឆ្ងាយពីម៉ាក់ឱ្យសោះណា!»

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C





ថ្ងៃមួយ ម្ដាយរបស់តូតូកំពុងដេកលង់លក់។ តូតូបានឃើញមេអំបៅពណ៌លឿងមួយក្បាលហើរកាត់
តូតូក៏រត់ដេញតាមមេអំបៅនោះយ៉ាងសប្បាយរីករាយ រហូតភ្លេចខ្លួន ធ្វើឱ្យវង្វេងផ្លូវ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



តូតូបានជួបនឹងសត្វស្វាមួយក្បាលឈ្មោះ ទីទី។

ទីទីសួរថា «អូ! កូនដំរីតូច! តើឯងឈ្មោះអី? ហើយឯងកំពុងទៅណាហ្នឹង?»

តូតូឆ្លើយ «ខ្ញុំឈ្មោះតូតូ! ខ្ញុំកំពុងដេញតាមមេអំបៅពណ៌លឿង! តើឯងចង់លេងជាមួយខ្ញុំទេ?»។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



តូតូនិងទីទីបានលេងបិទពួនជាមួយគ្នាយ៉ាងសប្បាយរីករាយ។
តូតូប្រើប្រមោយដ៏វែងរបស់វាបាញ់ទឹកដាក់ទីទី ដូចជាការងូតទឹកផ្កាឈូកអ៊ីចឹង។



មិនយូរប៉ុន្មាន មេឃចាប់ផ្ដើមងងឹត តូតូចង់ត្រឡប់ទៅផ្ទះវិញ ប៉ុន្តែវារកផ្លូវមិនឃើញនោះទេ។ តូតូចាប់ផ្ដើមភ័យ ហើយនិយាយទាំងចង់យំថា «ម៉ាក់ៗ! ម៉ាក់នៅឯណា?» ទីទីនិយាយថា «កុំខ្លាចអីតូតូ! ខ្ញុំនឹងជួយឯង»។ ទីទីបានឡើងលើចុងឈើខ្ពស់បំផុត ដើម្បីរកមើលម្ដាយរបស់តូតូ។



ទីទីបានឃើញព្រះអាទិត្យកំពុងរៀបលិច ហើយឃើញម្ដាយរបស់តូតូ និងឮសំឡេងហៅ «តូតូៗ! កូននៅទីណា?»។ ទីទីស្រែក «តូតូៗ! មើលហ្នុ៎»។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



តូតូបានរត់ទៅរកម្ដាយរបស់វាយ៉ាងលឿន។ ម្ដាយតូតូបានយកប្រមោយឱបតូតូយ៉ាងកក់ក្ដៅ។
តូតូនិយាយថា «កូនសុំទោស ម៉ាក់ៗ! ដែលកូនមិនស្ដាប់ដិបូន្មានរបស់ម៉ាក់
កូននឹងមិនដើរចេញឆ្ងាយទៀតទេ»។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



យប់នោះ ដូដូបានគេងលក់យ៉ាងស្កប់ស្កល់ក្បែរជើងម្ដាយរបស់វា។ ដូដូដឹងថាគ្មានកន្លែងណាដែលមានសុវត្ថិភាព និងកក់ក្ដៅជាងការនៅក្បែរម្ដាយរបស់វានោះឡើយ។